CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៦ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ជំនួយឥតសំណងរបស់រដ្ឋដើម្បីបង្កើនជំនួយសម្រាប់អ្នករស់នៅទីក្រុងឡុងប៊ិចដែលគ្មានការងារធ្វើ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះទីក្រុងឡុងប៊ិចបានប្រកាសថាបានទទួលជំនួយឥតសំណងចំនួន ៣ របស់រដ្ឋដែលមានទឹកប្រាក់សរុបជិត ២ លានដុល្លារដែលនឹងជួយដល់ Pacific Gateway ដែលជាតំបន់អភិវឌ្ឍន៍កម្លាំងពលកម្មដែលកំណត់ដោយសហព័ន្ធនិងគ្រប់គ្រងដោយទីក្រុងឡុងប៊ិច-ពង្រីកជំនួយដល់ប្រជាជនដែលការងាររបស់ពួកគាត់បានរងផលប៉ះពាល់ដោយសារតែ COVID-19។

លោក John Keisler ប្រធានបន្ទីអភិវឌ្ឍន៍សេដ្ឋកិច្ចបានមានប្រសាសន៍ថា "ទ្វារនៃមជ្ឈមណ្ឌលការងាររបស់យើងបានបន្តបើកចំហរចាប់តាំងពីជម្ងឺរាតត្បាតនេះចាប់កើតមានឡើងរហូតមកដល់ពេលនេះគឺមិនទាន់បិទនៅឡើយទេ។ នេះជាពេលវេលាប្រវត្តិសាស្រ្តហើយយើងក៏ត្រូវការការឆ្លើយតបជាប្រវត្តិសាស្រ្តផងដែរ។ ជំនួយថ្មីទាំងនេះនឹងផ្តល់នូវធនធានចាំបាច់ដល់អ្នកធ្វើការនិងក្រុមគ្រួសារដែលរងផលប៉ះពាល់ដោយ COVID-19។

អត្រាគ្មានការងារធ្វើដូចដែលបានផ្សព្វផ្សាយដោយរដ្ឋកាលីហ្វ័រញ៉ាដែលមានចំនួន 20.9% គឺជាអត្រាខ្ពស់បំផុតមិនធ្លាប់មានពីមុនមកសម្រាប់ទីក្រុងឡុងប៊ិចប៉ុន្តែមានកត្តាមួយចំនួនដែលបង្ហាញថាអត្រាគ្មានការងារធ្វើពិតប្រាកដគឺអាចខ្ពស់ជាងនេះ។

លោក Nick Schultz នាយកប្រតិបត្តិប្រចាំនៅ Pacific Gateway បានមានប្រសាសន៍ថា "អត្រាគ្មានការងារធ្វើនាពេលបច្ចុប្បន្ននេះគ្រាន់តែជាផ្នែកមួយនៃរឿងរ៉ាវប៉ុណ្ណោះនៅពេលដែលយើងនិយាយអំពីភាពអត់ការងារធ្វើ។ ចន្លោះពីថ្ងៃទី ១២ ខែមេសាដល់ថ្ងៃទី ១៣ ខែមិថុនាចំនួនកម្លាំងពលកម្មស៊ីវិលនៅឡុងប៊ិចថយចុះចំនួន 13,300 អ្នក។ ពលរដ្ឋទាំង 13,300 នាក់កំពុងតែទទួលមូលនិធិគ្មានការងារធ្វើ ទោះបីជាពួកគាត់មិនបានរាប់បញ្ចូលក្នុងអត្រារបស់យើងដោយសារតែពួកគាត់មិនបានស្វែងរកការងារធ្វើយ៉ាងសកម្មដោយកំពុងរង់ចាំគេហៅឱ្យទៅធ្វើការវិញ។ រាប់បញ្ចូលទាំងក្រុមនេះអត្រាគ្មានការងារធ្វើតរបស់យើងគឺកើនយ៉ាងហោចណាស់ក៏ដល់ 27%។

ជំនួយឥតសំណងដែលសរុបមានចំនួន $1.92 លានដុល្លារនឹងជួយបង្កើនសេវាកម្មនៅ The WorkPlace ដែលជាមជ្ឈមណ្ឌលអាជីពមួយដែលគ្រប់គ្រងដោយ Pacific Gateway។ សេវាកម្មដែលផ្តល់ជូនរួមមានការប្រឹក្សាការងារឱកាសបណ្តុះបណ្តាលវគ្គសិក្សាតាមអ៊ិនធរណេតនិងជំនួយក្នុងការស្វែងរកការងារថ្មី។ កម្មវិធីទាំងនេះក៏រួមបញ្ចូលទាំងសេវាកម្មជួយដល់តម្រូវការចាំបាច់ផ្សេងៗ។

ប្រហែលពាក់កណ្តាលនៃថវិកាជំនួយជិតមួយលានដុល្លារនឹងត្រូវទុកដោយឡែកដើម្បីជួយដល់កម្មករដែលរងផលប៉ះពាល់នៅក្នុងឧស្សាហកម្មអាកាសចរណ៍ដែលជាវិស័យសំខាន់មួយនៅក្នុងសេដ្ឋកិច្ចរបស់ទីក្រុង។ ថវិកាទាំងនេះនឹងជួយដល់និយោជិកដែលត្រូវបានបញ្ឈប់ការងារឱ្យរកការងារថ្មីនៅក្នុងវិស័យអាកាសចរណ៍ឬឧស្សាហកម្មផ្សេងទៀតដែលជំនាញរបស់ពួកគាត់អាចផ្ទេរទៅបាន។

Pacific Gateway នឹងធ្វើឱ្យធនធានមានយ៉ាងទូលំទូលាយសម្រាប់ក្រុមគ្រួសារនៅទូទាំងទីក្រុងដោយធ្វើការតាមរយៈបណ្តាញនៃក្រុមអង្គការមិនស្វែងរកប្រាក់ចំណេញរួមមាន Goodwill, Long Beach Center for Economic Inclusion, Centro CHA, Long Beach Job Corps, Long Beach Community Action Partnership និង Long Beach Immigrant Rights Coalition ក្នុងចំណោមអង្គការដទៃទៀត។

ប្រជាពលរដ្ឋដែលចាប់អារម្មណ៍ក្នុងការទទួលសេវាកម្មគាំទ្រពី The WorkPlace អាចទូរស័ព្ទមកលេខ 562.570.3700 ឬចូលអានព័ត៌មានតាមអ៊ិនធឺណែតតាមរយៈគេហទំព័រ៖ Pacific-Gateway.org។ សម្រាប់ព័ត៌មានបន្ថែមអំពីប្រតិបត្តិការផ្នែកអាជីវកម្មក្នុងអំឡុងពេល COVID-19 អ្នកធ្វើការនៅឡុងប៊ិច

និងម្ចាស់អាជីវកម្មអាចទូរស័ព្ទមកលេខ 562.570.4BIZ (4249) ឬចូលទៅកាន់គេហទំព័រ៖ longbeach.gov/4BIZ។

សម្រាប់ព័ត៌មានថ្មីៗអំពីជម្ងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #